

# ធ្វើការខាររហូតជំពាក់បំណុលវ័ណ្ឌកៈ

## ភាពជំពាក់បំណុលច្រើនលើសលុបក្នុងវិស័យកាត់ដេរនៅប្រទេសកម្ពុជា

របាយការណ៍សង្ខេបរួម  ចេញផ្សាយ ខែមិថុនា ឆ្នាំ២០២០

របាយការណ៍សង្ខេបរួម ចេញផ្សាយ ខែមិថុនា ឆ្នាំ២០២០

សហព័ន្ធសហជីពកម្ពុជា
CAMBODIAN ALLIANCE OF TRADE UNIONS

មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស
CENTRAL
CENTER FOR ALLIANCE OF
LABOR AND HUMAN RIGHTS

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធសហជីពកម្ពុជា ( CATU )

សម្ព័ន្ធសហជីពកម្ពុជា គឺជាសហព័ន្ធសហជីពឯករាជ្យមួយ ដែលបានចុះបញ្ជីស្របតាមច្បាប់ តំណាងឱ្យកម្មករ កម្មការិនី ក្នុងវិស័យផលិតកម្ម នៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ២០១១។ សម្ព័ន្ធសហជីពកម្ពុជា តំណាងឱ្យកម្មករ កម្មការិនី រោងចក្រកាត់ដេរ សំលៀកបំពាក់ ស្បែកជើង សម្ភារៈធ្វើដំណើរ និងកាបូប នៅក្នុងប្រទេសកម្ពុជា។ សម្ព័ន្ធសហជីពកម្ពុជា បានជួយកម្មករ កម្មការិនី រាប់ម៉ឺននាក់ ដើម្បីទទួលបានអត្ថប្រយោជន៍ច្រើនជាងអ្វីដែលច្បាប់បានកំណត់ និងផ្លាស់ប្តូរការប្រើប្រាស់កិច្ចសន្យាការងាររយៈពេលខ្លី ទៅជាកិច្ចសន្យាការងារមិនមានថេរវេលាកំណត់ និងការលើកកម្ពស់សុខុមាលភាព និងលក្ខខណ្ឌសុវត្ថិភាពនៅកន្លែងធ្វើការ។ សម្ព័ន្ធសហជីពកម្ពុជា ក៏បានជួយកម្មករ កម្មការិនី រាប់ពាន់នាក់ ឱ្យបានត្រឡប់ចូលមកធ្វើការវិញ ក្នុងនោះមានអ្នកដែលទទួលរងការរើសអើងពីការមានផ្ទៃពោះ ឬសកម្មភាពការងារសហជីពផងដែរ។

## មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ( សង់ត្រាល់ )

អង្គការសង់ត្រាល់ ផ្តល់អំណាចដល់ប្រជាពលរដ្ឋខ្មែរជាអ្នកធ្វើការងារ ដើម្បីឱ្យពួកគាត់ទាមទារអោយមានអភិបាលកិច្ចប្រកបដោយ តម្លាភាព និងគណនេយ្យភាពសម្រាប់វិស័យការងារ និងសិទ្ធិមនុស្សតាមរយៈការផ្តល់ជំនួយផ្នែកច្បាប់និងមធ្យោបាយសមស្របដទៃទៀត។ ចក្ខុវិស័យនៃអង្គការនេះគឺថា ប្រជាពលរដ្ឋកម្ពុជាជាម្ចាស់នៃប្រទេស រស់នៅជាមួយសេចក្តីថ្លៃថ្នូរក្នុងភាពជាមនុស្ស និងសន្តិភាព។ អង្គការសង់ត្រាល់ ចងក្រង និងគាំទ្រក្រុមអ្នកធ្វើការងារតាមរយៈ ការផ្តល់ជំនួយផ្នែកច្បាប់ និងមធ្យោបាយសមរម្យផ្សេងទៀត ដើម្បីទទួលបានអភិបាលកិច្ចដែលប្រកបដោយតម្លាភាព និងគណនេយ្យភាពសម្រាប់សិទ្ធិការងារ និងសិទ្ធិមនុស្ស ដើម្បីរួមចំណែកឱ្យមានអភិបាលកិច្ចប្រកបដោយ តម្លាភាព និងគណនេយ្យភាព សម្រាប់សិទ្ធិមនុស្ស និងសិទ្ធិកម្មករ កម្មការិនី នៅក្នុងប្រទេសកម្ពុជា។

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។  ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការលីកាដូគឺស្ថិតនៅជួរមុខគេ ក្នុងកិច្ចខិតខំប្រឹងប្រែង ការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គម នៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់  ការគោរពសិទ្ធិទាំងនេះ ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នពាក់ព័ន្ធនានា។  ដោយបានកសាងនូវ សមិទ្ធផលល្អក្នុងអតីតកាល  អង្គការលីកាដូ  បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋកម្ពុជា  និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស របស់ការិយាល័យកណ្តាលរបស់ខ្លួននៅក្នុងរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១៣ ខេត្តផ្សេងទៀត។

# មាតិកា

ខ្លឹមសារសង្ខេប ទំព័រ ១

វិធីសាស្ត្រ ទំព័រ ៤

ការរកឃើញនៃការសិក្សា ទំព័រ ៤

អនុសាសន៍ ទំព័រ ១០

*ការស្រាវជ្រាវនេះគឺមិនត្រូវបានធ្វើឡើងក្នុងគោលបំណងតំណាងឱ្យតួលេខទាំងអស់នៅក្នុងប្រទេសកម្ពុជា ឬតំណាងឱ្យអតិថិជនទាំងអស់នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាទេ។ របាយការណ៍នេះគ្រាន់តែត្រូវបានធ្វើឡើង ដើម្បីបង្ហាញអំពីបញ្ហាមួយចំនួនដែលអ្នកស្រាវជ្រាវបានរកឃើញនៅតាមក្រុមគោលដៅ ដូចជា កម្មករ កម្មការិនី រោងចក្រកាត់ដេរ ដែលធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋកម្ពុជាជាច្រើននាក់។*

# ខ្លឹមសារសង្ខេប

កម្មករ កម្មការិនី នៃវិស័យកាត់ដេរនៅក្នុងប្រទេសកម្ពុជា កំពុងរងគ្រោះយ៉ាងធ្ងន់ធ្ងរពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដែលបណ្តាលមកពីការរីករាលដាលនៃវីរុសកូវីដ១៩ ។ ដោយសារកម្មករ កម្មការិនី នៅក្នុងវិស័យមួយនេះនៅតែទទួលបានប្រាក់ខែតិចអស់រយៈពេលជាច្រើនឆ្នាំមកហើយនោះ ទើបជំរុញឱ្យពួកគាត់ពឹងផ្អែកលើការខ្ចីប្រាក់ ដើម្បីជួយផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ដែលភាគច្រើននៃប្រាក់កម្ចីទាំងនេះ គឺផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយត្រូវដាក់ប័ណ្ណសម្គាល់កម្មសិទ្ធិ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី របស់ម្ចាស់ទ្រព្យធ្វើជាទ្រព្យធានា ។ កម្មករ កម្មការិនី រាប់សែននាក់ ដែលកំពុងជំពាក់បំណុលគេយ៉ាងច្រើនបានបាត់បង់ការងារបន្ទាប់ពីរោងចក្រកាត់ដេររាប់រយរោងចក្របានផ្អាកដំណើរការ។ បញ្ហានេះបានធ្វើឱ្យពួកគាត់ប្រឈមនឹងហានិភ័យនៃការបាត់បង់ដីធ្លី និងការរំលោភសិទ្ធិមនុស្សដទៃទៀត។ វិស័យមួយនេះក៏បាន ទទួលរងផលប៉ះពាល់ដោយសារការសម្រេចដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធលើទំនិញគ្រប់មុខលើកលែងតែសព្វាវុធ (EBA) កាលពីខែកុម្ភៈ ឆ្នាំ២០២០ កន្លងទៅនេះផងដែរ ។ សេចក្តីសម្រេចនេះធ្វើឡើងបន្ទាប់ពី សហភាពអឺរ៉ុបដែលជាទិសដៅនាំចេញធំបំផុតមួយរបស់វិស័យកាត់ដេរនេះ បានរកឃើញថា "មានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងជាលក្ខណៈប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា" ។

លទ្ធផលនៃការស្រាវជ្រាវនេះ បានមកពីការស្ទង់មតិទៅលើកម្មករកម្មការិនីកាត់ដេរចំនួន១៦២នាក់ (ស្ត្រី១៥៨នាក់) ហើយការស្ទង់មតិនេះធ្វើឡើងនៅចន្លោះខែមីនា និងខែឧសភា ឆ្នាំ២០២០។ កម្មករកម្មការិនី ដែលបានចូលរួមក្នុងការសិក្សានេះ មកពីរោងចក្រកាត់ដេរចំនួន៣ផ្សេងគ្នា ដែលរោងចក្រខ្លះបានព្យួរការងារដោយផ្នែក និងខ្លះទៀតបានព្យួរការងារទាំងស្រុង ។ អ្នកស្រាវជ្រាវបានរកឃើញថា ពីរភាគបីនៃកម្មករ កម្មការិនី ត្រូវបង់សងកម្ចីឥណទានយ៉ាងតិចណាស់ក៏មួយកន្លែង

> "មន្ត្រីឥណទាន [មកពីធនាគារស្ថាបនា] បានប្រាប់ខ្ញុំឱ្យខ្ចីប្រាក់ពីកន្លែងផ្សេងដើម្បីយកមកសងបំណុលនៅស្ថាប័នគាត់ ។"

ដែរ ។ ពួកគាត់ត្រូវយកប្រាក់ចំណូលភាគច្រើនដែលរកបាននៅមុនពេលព្យួរការងារ ដើម្បីបង់សងកម្ចីឥណទានទាំងនេះ ។ គិតជាមធ្យម ចំនួនប្រាក់បង់សងបំណុល និងប្រាក់សម្រាប់ចំណាយលើថ្លៃម្ហូបអាហារប្រចាំខែ មានចំនួនច្រើនជាងប្រាក់ខែរបស់ពួកគាត់ ទៅទៀតដូច្នេះពួកគាត់ត្រូវកាត់បន្ថយការចំណាយលើថ្លៃម្ហូបអាហារដើម្បីសន្សំប្រាក់ទុកបង់សងបំណុលវិញ ។ ៩៦% នៃអ្នកផ្តល់បទសម្ភាសន៍ដែលជាប់ជំពាក់កម្ចីឥណទានខ្នាតតូចបាននិយាយថា ជីវភាពរស់នៅរបស់ពួកគាត់ "លំបាកខ្លាំង" (៨០%) ឬ "លំបាកតិចតួច" (១៦%) នៅក្នុងពេលបច្ចុប្បន្ន បើប្រៀបធៀបទៅនឹងពេលដែលពួកគាត់មិនទាន់ជាប់ជំពាក់កម្ចីឥណទានខ្នាតតូច ។ អ្នកផ្តល់បទសម្ភាសន៍ត្រឹមតែ ២% ប៉ុណ្ណោះដែលនិយាយថា ជីវភាពរស់នៅរបស់ពួកគាត់ "ប្រសើរជាងមុនបន្តិច" និងគ្មាននរណាម្នាក់និយាយថា ជីវភាពរស់នៅរបស់ពួកគាត់ "ប្រសើរខ្លាំង" នោះទេ ។

> " ខ្ញុំគ្មានសង្ឃឹមថានឹងមានការងារធ្វើវិញទេ ។ ខ្ញុំពិតជាបារម្ភចំពោះគ្រួសាររបស់ខ្ញុំណាស់ ហើយមិនដឹងថាអាចរកប្រាក់មកពីណា ដើម្បីចំណាយលើថ្លៃម្ហូបអាហារ ថ្លៃជួលផ្ទះ ថ្លៃព្យាបាលជំងឺ និងការបង់សងបំណុលធនាគារ និងអ្នកចងការប្រាក់ឯកជនបាននោះទេ។"

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារពាណិជ្ជកម្ម និងដៃគូវិនិយោគ ដែលភាគច្រើនគឺជាទីភ្នាក់ងារអភិវឌ្ឍន៍ ឬជាធនាគាររដ្ឋរបស់ប្រទេសនៅទ្វីបអឺរ៉ុប គឺជាអ្នកទទួលខុសត្រូវចំពោះការជំពាក់បំណុលច្រើនលើសលុបស្ទើរតែគ្រប់ទីកន្លែងនៅប្រទេសកម្ពុជា ។ ស្ថាប័នទាំងនេះ នៅតែបន្តផ្តល់មូលនិធិ ដើម្បីពង្រីកយ៉ាងគំហុកនូវវិស័យឥណទានខ្នាតតូច និងទំហំកម្ចីផលប័ត្រឥណទាន បើទោះជាអ្នកសេដ្ឋកិច្ច និងអង្គការសិទ្ធិមនុស្ស ធ្លាប់បានព្រមានពីការផ្តល់ប្រាក់កម្ចីច្រើនហួសហេតុ និងការរំលោភបំពាន នៅក្នុងវិស័យនេះក៏ដោយ ។ គិតត្រឹមបំណាច់ឆ្នាំ២០១៩នេះ ប្រជាពលរដ្ឋកម្ពុជាជាង ២លាន៦សែននាក់ កំពុងជាប់ជំពាក់កម្ចីឥណទានខ្នាតតូចជាង១០ពាន់លានដុល្លារ ជាមួយនឹងអត្រាកម្ចីជាមធ្យម ៣.៨០៤ ដុល្លារ ដែលជាចំនួនច្រើនជាងគេនៅលើពិភពលោក និងខ្ពស់ជាងផលិតផលសរុបក្នុងស្រុក (GDP) ឬចំណូលប្រចាំឆ្នាំ សម្រាប់មនុស្សម្នាក់។

នៅក្នុងអំឡុងពេលនៃការរីករាលដាលនៃវីរុសកូវីដ១៩ ដៃគូអភិវឌ្ឍន៍គួរអនុវត្តកម្មវិធីសម្រាលបន្ទុកបំណុលដល់ប្រជាពលរដ្ឋកម្ពុជា ដែលកំពុងជួបការលំបាក ។ ផ្ទុយទៅវិញ ដៃគូអភិវឌ្ឍន៍ទាំងនេះ បែរជាបន្តពង្រីកវិស័យឥណទានខ្នាតតូច ដែលមានទំហំធំហួសហេតុស្រាប់ទៅវិញ ។ នៅក្នុងខែមករា ឆ្នាំ២០២០ មានការចេញផ្សាយសេចក្តីប្រកាសព័ត៌មានមួយថា នាយកដ្ឋានកិច្ចការបរទេស និងពាណិជ្ជកម្ម (DFAT) របស់ប្រទេសអូស្រ្តាលី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (US-AID) និងអង្គការសហប្រជាជាតិបានសហការគ្នាដើម្បីគាំទ្រគម្រោងមួយមានឈ្មោះថា មូលបត្របំណុល២សម្រាប់ជីវភាពរស់នៅរបស់ស្ត្រី (Women's Livelihood Bond 2) ដែលបានផ្តល់មូលនិធិប្រមាណជា ៦លានដុល្លារដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងខែមីនា DEG ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុដើម្បីអភិវឌ្ឍន៍របស់ប្រទេសអាឡឺម៉ង់ និងជាសាខារបស់ធនាគាររដ្ឋដើម្បីអភិវឌ្ឍន៍ដែលហៅកាត់ថា KfW បានប្រកាសថាខ្លួននឹងផ្តល់ប្រាក់កម្ចីចំនួន១៨លានដុល្លារដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំបំផុតមួយនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងខែមេសា សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) របស់ធនាគារពិភពលោក បានស្នើសុំមូលនិធិចំនួន១៥លានដុល្លារ

ឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំបំផុតមួយផ្សេងទៀត នៅក្នុងប្រទេសកម្ពុជា។ គោលបំណងនៃការផ្តល់មូលនិធិនេះ គឺដើម្បីលើកកម្ពស់ឱកាសទទួលបានហិរញ្ញវត្ថុដល់ស្ត្រីនៅកម្ពុជា។ ប៉ុន្តែអ្វីដែលប្រជាពលរដ្ឋកម្ពុជាអ្នកខ្ចីប្រាក់ត្រូវការនាពេលបច្ចុប្បន្ននេះ គឺកម្មវិធីសម្រាលបន្ទុកបំណុលមិនមែនជាទឹកប្រាក់រាប់លានដុល្លារដែលប្រើសម្រាប់បង្កើនប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលភាគច្រើន ជាកម្មសិទ្ធិរបស់ជនបរទេស ដើម្បីពង្រីកទំហំផលប័ត្រឥណទានរបស់ខ្លួននោះឡើយ ។

យើងខ្ញុំជំរុញឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងទីភ្នាក់ងារអភិវឌ្ឍន៍ទាំងនេះ ចាត់វិធានឱ្យបានឆាប់បំផុត ដើម្បីកាត់បន្ថយបន្ទុកបំណុលរបស់ប្រជាពលរដ្ឋកម្ពុជា និងសម្រាលទុក្ខវេទនារបស់អ្នកខ្ចីប្រាក់ផងដែរ ។

ការស្រាវជ្រាវនេះមិនបានរកឃើញភស្តុតាងណាមួយ ដែលគាំទ្រនូវការអះអាងថា ឥណទានខ្នាតតូច ចូលរួមជួយបង្កើនប្រាក់ចំណូលរបស់អ្នកខ្ចីប្រាក់នោះទេ ។ ហេតុផលចម្បងដែលគេជំពាក់ប្រាក់កម្ចីឥណទានគឺដើម្បី "សាងសង់ផ្ទះ" ដើម្បី "សងបំណុល" និងដោយសារ "ហេតុផលផ្សេងៗ" (ភាគច្រើនគឺយកទៅទិញទ្រព្យសម្បត្តិដូចជាម៉ូតូ ឬដីធ្លីជាដើម) ។ ការខ្ចីប្រាក់ឥណទាន "ដើម្បីធ្វើអាជីវកម្ម" "ដើម្បីព្យាបាលជំងឺ" និង "ដើម្បីធ្វើកសិកម្ម" មានតិចតួចបំផុត ។ ការរកឃើញនេះ បានចោទជាសំណួរថាតើមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប៉ុន្មានភាគរយ ដែលមិនតម្រូវថា កម្ចីឥណទាន គឺផ្តល់ឱ្យសម្រាប់យកទៅប្រើប្រាស់ ដើម្បីបង្កើនប្រាក់ចំណូល ប៉ុន្តែបែរជាពឹងផ្អែកលើសុវត្ថិភាពប័ណ្ណសម្គាល់កម្មសិទ្ធិ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី របស់អ្នកខ្ចីប្រាក់ដើម្បីធានា ការបង់សងកម្ចីឥណទានត្រឡប់មកវិញ ។ កម្មករ កម្មការិនី រោងចក្រ ១៦នាក់ ដែលជាអ្នកជំពាក់កម្ចីឥណទានខ្នាតតូច បានលក់ដីរបស់ពួកគាត់ ដើម្បីសងបំណុល ហើយកម្មករ កម្មការិនី ៣៣នាក់ផ្សេងទៀត គ្រោងនឹងលក់ដីដើម្បីសងបំណុលនៅក្នុងពេលឆាប់ៗខាងមុខនេះ ។

"ខ្ញុំពិតជាព្រួយបារម្ភចំពោះការបង់ប្រាក់សងកម្ចីធនាគារអេស៊ីលីដា និងម្ចាស់បំណុលផ្សេងទៀតណាស់ ។ ប្រសិនបើខ្ញុំគ្មានលទ្ធភាពសងទេ នោះគេនឹងរឹបអូសផ្ទះនិងដីលំនៅដ្ឋានរបស់ខ្ញុំហើយ ។"

ការលក់ដីដោយការរងសម្ពាធនៅតែបន្តកើតមាន បើទោះជាមានវិធានការពីធនាគារជាតិ កាលពីខែមីនាកន្លងទៅ ដោយបានជំរុញឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោះស្រាយបញ្ហាកម្ចីឥណទានជាមួយអ្នកខ្ចីប្រាក់ ដែលកំពុងជួបការលំបាកតាមភាពជាក់ស្តែង ។ នៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ធនាគារជាតិ បានជួយដោះស្រាយបញ្ហារបស់អ្នកខ្ចីប្រាក់មួយចំនួនដែលបានដាក់ពាក្យបណ្តឹងផ្លូវការ ចំពោះការដាក់សម្ពាធដោយមិនសមហេតុផលពីសំណាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ចំណាត់ការបែបនេះ បានចូលរួមជួយសម្រាលបន្ទុករបស់អ្នកខ្ចីប្រាក់ទាំងនោះ ប៉ុន្តែមានអ្នកខ្ចីប្រាក់រាប់សែននាក់ផ្សេងទៀត ក្នុងនោះមានកម្មករ កម្មការិនី រោងចក្រផងដែរ ដែលពុំបានដាក់ពាក្យបណ្តឹងផ្លូវការណាមួយ ដោយសារខ្វះមធ្យោបាយខ្វះព័ត៌មាន និង/ឬ ខ្វះចំណេះដឹងស្តីពីនីតិវិធី នៃការដាក់ពាក្យបណ្តឹងនេះ។ យើង

## *ការលក់ដីដើម្បីសងបំណុល*

*អ្នកស្រី សុភា អាយុ ៤០ឆ្នាំ គឺជាកម្មការិនីរោងចក្រធ្វើការនៅក្នុងរោងចក្រកាត់ដេរមួយនៅក្នុងរាជធានីភ្នំពេញ ។ ប្រាក់ខែរបស់អ្នកស្រីបានជួយឱ្យអ្នកស្រីមានលទ្ធភាពចិញ្ចឹមកូនពីរនាក់ ក្នុងនោះមានម្នាក់ជាមនុស្សពេញវ័យ និងម្នាក់ទៀតទើបតែមានអាយុ៦ឆ្នាំ ។ ប៉ុន្តែប្រាក់ខែរបស់អ្នកស្រីមិនអាចបំពេញតម្រូវការប្រចាំថ្ងៃគ្រប់គ្រាន់នោះទេ ដូច្នេះអ្នកស្រីបានខ្ចីឥណទានខ្នាតតូចពីធនាគារអេស៊ីលីដា ដើម្បីប្រកបរបរលក់ដូរតាមអ៊ីនធឺណេត ។ ក្រុមគ្រួសាររបស់អ្នកស្រីបានធ្លាក់ក្នុងស្ថានភាពលំបាកនៅពេលប្តីរបស់អ្នកស្រី ដែលជាអ្នករកស៊ីម៉ៅការសំណង់ ចាញ់បោកថៅកែសំណង់ ។ ដូច្នេះអ្នកស្រីក៏បានទៅខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយផ្សេងទៀតគឺ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ ដោយគាត់បានប្រាប់គ្រឹះស្ថាននេះថា គាត់ចង់បានកម្ចីឥណទានមួយ ដើម្បីយកទៅសងកម្ចីឥណទានរបស់ធនាគារអេស៊ីលីដា ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ ដែលបានលក់ហ៊ុន និងប្តូរឈ្មោះទៅជា ដាប់ប៊ែលយូប៊ី ហ្វាយនែន ក៏បានយល់ព្រម។*

*នៅក្នុងខែមេសា ឆ្នាំ២០២០ ថៅកែរោងចក្ររបស់អ្នកស្រីបានព្យួរការងារបុគ្គលិកដោយសារតែការរីករាលដាលនៃវីរុសកូវីដ១៩ ។ បញ្ហានេះបានធ្វើឱ្យគ្រួសារអ្នកស្រីបាត់បង់ប្រាក់ចំណូល និងគ្មានលទ្ធភាពបង់សងកម្ចីឥណទានវិញទេ ។ ដំបូងមន្ត្រីឥណទានរបស់ដាប់ប៊ែលយូប៊ី ហ្វាយនែន បានយល់ព្រមផ្អាកការបង់សងប្រាក់កម្ចីរយៈពេល៦ខែ ប៉ុន្តែភ្លាមៗក្រោយពីបានយល់ព្រមដូច្នេះ មន្ត្រីរូបនោះបានទាក់ទងមកអ្នកស្រីវិញថា "ថ្នាក់លើរបស់គាត់មិនយល់ព្រមទេ" និងទទូចឱ្យអ្នកស្រីសងកម្ចីឥណទានទាំងអស់វិញ ។ មន្ត្រីឥណទានដដែលបន្តថា "ប្រសិនបើអ្នកស្រីគ្មានលទ្ធភាពសងប្រាក់កម្ចីវិញទេ អ្នកស្រីត្រូវតែលក់ដី"។ ដោយការភ័យខ្លាច ព្រោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនេះបានកាន់កាប់ប័ណ្ណសម្គាល់កម្មសិទ្ធិ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី ដែលជាទ្រព្យធានា អ្នកស្រីបានសម្រេចលក់ដីស្រែរបស់អ្នកស្រីនៅឯស្រុកកំណើត ដើម្បីយកប្រាក់សងកម្ចីឥណទានរបស់ ដាប់ប៊ែលយូប៊ី ហ្វាយនែនវិញ ។ អ្នកស្រីនិយាយថា "វាពិតជាឈឺចាប់" "វាពិតជាលំបាកណាស់" ។*

ជំរុញឱ្យធនាគារជាតិ ជួយគាំទ្រដល់កម្មករ កម្មការិនី រោងចក្រដែលកំពុងជួបប្រទះការលំបាកក្នុងជីវភាពរស់នៅតាមរយៈ ការអនុវត្តនូវវិធានការផ្លូវច្បាប់ដែលគ្របដណ្តប់លើគ្រប់វិស័យ រួមមានការផ្អាកបង់សងប្រាក់កម្ចី និងការប្រាក់ជាបណ្តោះអាសន្ន ដើម្បីធានាថាពុំមានកម្មករ កម្មការិនី ណាម្នាក់រងគ្រោះដោយសារបញ្ហានេះ ។

វិធីសាស្ត្រផ្សេងទៀតដែលកម្មករ កម្មការិនី តែងអនុវត្ត ដើម្បីសន្សំប្រាក់ទុកបង់សងកម្ចីឥណទាន រួមមានការកាត់បន្ថយចំណាយលើថ្លៃម្ហូបអាហារ ការខ្ចីប្រាក់បន្ថែម និងការធ្វើចំណាកស្រុកដើម្បីរកការងារធ្វើជាដើម។ កម្មករ កម្មការិនី ដែលផ្តល់បទសម្ភាសន៍ភាគច្រើននិយាយថា ពួកគាត់នឹងអនុវត្តវិធីសាស្ត្របែបនេះនៅពេលខាងមុខ ដែលការអនុវត្តបែបនេះធ្វើឱ្យពួកគាត់ប្រឈមនឹងហានិភ័យកាន់តែខ្ពស់ ។ វិបត្តិសិទ្ធិមនុស្សនេះនឹងកាន់តែធ្ងន់ធ្ងរឡើង ប្រសិនបើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅតែបន្តធ្វើឱ្យពួកគាត់ប្រឈមនឹងការរងសម្ពាធផ្នែកសេដ្ឋកិច្ចនេះ ។

ក្រៅពីជាប់ជំពាក់កម្ចីឥណទានខ្នាតតូច កម្មករ កម្មការិនី រោងចក្រ ដែលចូលរួមក្នុងការស្ទង់មតិនេះ ក៏បានខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជន ឬសាច់ញាតិ បើទោះជាករណីបែបនេះពុំសូវមានច្រើនដូចកម្ចីឥណទានក្តី ។

ប្រាក់កម្ចីក្រៅផ្លូវការទាំងនេះ មានទំហំតូចជាងកម្ចីឥណទាន និងជាទូទៅមិនទាមទារឱ្យមានទ្រព្យធានានោះទេ ហើយអ្នកខ្ចីប្រាក់ភាគច្រើនមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងបំណុលប្រភេទនេះ។ លើសពីនេះទៅទៀត មូលហេតុទូទៅនៃការចងការប្រាក់ឯកជនគឺដើម្បីយកទៅ "បង់សងបំណុលដែលមានស្រាប់" ដែលមូលហេតុនេះបង្ហាញឱ្យឃើញថាអ្នកជំពាក់ប្រាក់កម្ចីជាញឹកញាប់ត្រូវចងការប្រាក់ឯកជនដើម្បីបង់សងកម្ចីឥណទានផ្លូវការ ។ ជាការពិត មូលហេតុសំខាន់ជាងគេនៃការចងការប្រាក់ឯកជន នៅក្នុងទម្រង់ណាក៏ដោយ គឺដើម្បីយកទៅសងបំណុលដែលមានស្រាប់ ដែលការអនុវត្តបែបនេះបង្ហាញឱ្យឃើញថា ទីផ្សារឥណទាននៅក្នុងប្រទេសកម្ពុជា មានបរិមាណធំហួសហេតុ គួរឱ្យព្រួយបារម្ភ។ បំណុលមីក្រូហិរញ្ញវត្ថុទំនងជាកត្តាជំរុញបន្ថែម ឱ្យអ្នកខ្ចីប្រាក់កាន់តែពឹងផ្អែកលើអ្នកចងការប្រាក់ឯកជនមិនផ្លូវការ ដែលផ្ទុយពីការអះអាងរបស់អ្នកផ្តល់កម្ចីឥណទានខ្នាតតូច ។

លទ្ធផលនៃការស្រាវជ្រាវដែលបានរកឃើញបញ្ហាជាច្រើន បានជំរុញឱ្យអ្នកស្រាវជ្រាវធ្វើការស្នើសុំជាថ្មីម្តងទៀត ឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងវិនិយោគិនអន្តរជាតិ ដែលបានចំណាយទឹកប្រាក់រាប់រយលានដុល្លារ និងបានបង្កជាបន្ទុក នៃការជាប់ជំពាក់បំណុលវ័ណ្ឌក ដល់ប្រជាពលរដ្ឋកម្ពុជាឱ្យដាក់ចេញឱ្យបានឆាប់នូវកម្មវិធីសម្រាលបន្ទុកបំណុល។ ទីភ្នាក់ងាររបស់រដ្ឋាភិបាល ដែលមានដូចជា BMZ និង KfW របស់ប្រទេសអាឡឺម៉ង់ FMO របស់ប្រទេសហូឡង់ SIDA របស់ប្រទេសស៊ុយអែត OeEB របស់ប្រទេសអូទ្រីស និងទីភ្នាក់ផ្សេងទៀត ដោយបូករួមទាំងដៃគូសហប្រតិបត្តិការទ្វេភាគី ដែលមានដូចជា សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និង ធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ ត្រូវទទួលស្គាល់ថា ការវិនិយោគដ៏សម្បើមនៅក្នុងវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា បាននាំឱ្យមានវិបត្តិនៅក្នុងវិស័យនេះ។ ដូច្នេះស្ថាប័នទាំងនេះ ត្រូវចាត់វិធានការឱ្យបានឆាប់រហ័សដើម្បីជួយគាំទ្រអ្នកខ្ចីប្រាក់ ដែលកំពុងរងគ្រោះដោយផ្ទាល់ ពីការវិនិយោគរបស់ពួកគេ។ យើងខ្ញុំក៏សូមស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជា ពង្រីកកម្មវិធីការពារប្រជាពលរដ្ឋដែលជាអ្នកខ្ចីប្រាក់ និងអនុវត្តឱ្យបានឆាប់រហ័សនូវវិធានការតាមផ្លូវច្បាប់ ដែលគ្របដណ្តប់លើគ្រប់វិស័យ រួមមានការផ្អាកជាបណ្តោះអាសន្ន នូវការបង់សងប្រាក់កម្ចីនិងការប្រាក់ និងការប្រគល់ប័ណ្ណសម្គាល់កម្មសិទ្ធិ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី ដែលបានដាក់ជាទ្រព្យធានាឱ្យម្ចាស់ទ្រព្យវិញ ព្រមទាំងយកចិត្តទុកដាក់ខ្ពស់ ចំពោះអ្នកខ្ចីប្រាក់ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ ដូចជាកម្មករ កម្មការិនី រោងចក្រកាត់ដេរជាដើម។ ចំណាត់ការនេះ ជាមធ្យោបាយដ៏ប្រសើរបំផុត ដើម្បីការពារសិទ្ធិមនុស្សរបស់អ្នកជំពាក់ប្រាក់កម្ចីខ្នាតតូចទាំងអស់ ជាពិសេសកម្មករ កម្មការិនី រោងចក្រកាត់ដេរ ដែលកំពុងគ្មានការងារធ្វើ ។

# វិធីសាស្ត្រ

នៅចន្លោះខែមីនា រហូតដល់ខែឧសភា ឆ្នាំ២០២០ អ្នកស្រាវជ្រាវបានសម្ភាសកម្មករ កម្មការិនី រោងចក្រកាត់ដេរចំនួន ១៦២នាក់ (ស្ត្រី១៥៨នាក់) ដែលជាសមាជិករបស់សម្ព័ន្ធសហជីពកម្ពុជា (CATU) មកពីរោងចក្រកាត់ដេរចំនួន ៣ផ្សេងគ្នា ។ ក្នុងនោះរោងចក្រចំនួន២ ស្ថិតនៅក្នុងរាជធានីភ្នំពេញ និងរោងចក្រទី៣ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ។ ដោយសារបញ្ហាវីរុសកូវីដ១៩ អ្នកស្រាវជ្រាវបានផ្តល់ម៉ាស់ ទឹកលាងដៃ ការពិនិត្យសីតុណ្ហភាពអ្នកចូលរួម និងរក្សាគម្លាតពីគ្នា ដើម្បីការពារខ្លួនឯង ក៏ដូចជាអ្នកផ្តល់បទសម្ភាសន៍ ។

ក្នុងការស្ទង់មតិនេះ អ្នកស្រាវជ្រាវបានសួរសំណួរជាច្រើនទៅកម្មករ កម្មការិនី រោងចក្រ ទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួន ថវិការបស់គ្រួសារ និងកម្ចីឥណទានជាដើម ។ អ្នកស្រាវជ្រាវស្នើឱ្យអ្នកចូលរួមបែងចែកឱ្យដាច់រវាងកម្ចីឥណទានខ្នាតតូច និងទម្រង់ផ្សេងទៀតនៃបំណុល (ដូចជាការខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជន និងការខ្ចីប្រាក់ពីសាច់ញាតិជាដើម)។ កម្មករកម្មការិនី ត្រូវបានប្រធានសហជីពក្នុងរោងចក្រនីមួយៗជ្រើសរើស ដោយផ្អែកលើលទ្ធភាព ដែលពួកគាត់អាចចូលរួមបាននៅក្នុងការសិក្សានេះនិងមិនត្រូវបានពិនិត្យជាមុនទៅលើកម្រិតបំណុល ឬព័ត៌មានទាក់ទងនឹងសេដ្ឋកិច្ច ឬសង្គមកិច្ចរបស់ពួកគាត់ នៅមុនពេលសិក្សាស្រាវជ្រាវឡើយ ។ កម្មករ កម្មការិនី ទាំងអស់ឆ្លើយសំណួរស្ទង់មតិរៀងៗខ្លួន ។

# ការរកឃើញនៃការសិក្សា

- ក្នុងចំណោមកម្មករ កម្មការិនី សរុប ១៦២នាក់ ដែលចូលរួមក្នុងការស្ទង់មតិនេះ មានកម្មករ កម្មការិនី ចំនួន ១៥៨នាក់ បានជំពាក់កម្ចីឥណទានយ៉ាងតិចមួយកន្លែង ។
- ភាគច្រើននៃប្រភេទកម្ចីទាំងនេះគឺជា កម្ចីឥណទានខ្នាតតូចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។ កម្មករ កម្មការិនី ចំនួន ១០៦ នាក់ (៦៥% នៃចំនួនកម្មករ កម្មការិនី សរុប) ជាប់ជំពាក់កម្ចីឥណទានយ៉ាងតិចមួយ ។
- ក្នុងចំណោមកម្មករ កម្មការិនី ចំនួន ១០៦ នាក់នេះ ភាគច្រើននៃពួកគាត់បានកាត់បន្ថយការចំណាយលើថ្លៃម្ហូបអាហារ (៧២%) ឬខ្ចីកម្ចីឥណទានផ្សេងមួយទៀត (៥១%) ដើម្បីយកមកសងកម្ចីឥណទានខ្នាតតូចរបស់ពួកគាត់ ត់ ។
- ក្នុងចំណោមកម្មករ កម្មការិនី ចំនួន ១០៦ នាក់នេះ មាន១៦នាក់ (១៥%) បានលក់ដី ដើម្បីសងកម្ចីឥណទានខ្នាតតូច ខណៈដែលកម្មករ កម្មការិនី ស្មើនឹងពីរដងនៃភាគរយនេះ មានគម្រោងលក់ដីនៅពេលខាងមុខ ។
- កម្មករ កម្មការិនី ៩៥% បាននិយាយថា ពួកគាត់គ្មានលទ្ធភាពសងកម្ចីឥណទានខ្នាតតូចទេ ប្រសិនបើរោងចក្រព្យួរការងាររបស់ពួកគាត់។
- កម្មករ កម្មការិនី ៩៦% បាននិយាយថា ជីវភាពរស់នៅរបស់ពួកគាត់កាន់តែលំបាកខ្លាំងឡើងៗ ឬលំបាកតិចតួច បន្ទាប់ពីជាប់ជំពាក់កម្ចីឥណទាន។
- មូលហេតុចម្បង ដែលពួកគាត់ខ្ចីកម្ចីឥណទានក្នុងប្រភេទណាក៏ដោយ គឺដើម្បីយកទៅសងកម្ចីឥណទានផ្សេងមួយទៀត។
- ការចំណាយជាមធ្យម សម្រាប់បង់សងកម្ចីឥណទាន និងការចំណាយលើថ្លៃម្ហូបអាហារមានចំនួន ច្រើនជាងប្រាក់ចំណូលជាមធ្យមរបស់ពួកគាត់ ។
- គិតជាមធ្យម កម្មករ កម្មការិនី ម្នាក់ត្រូវផ្គត់ផ្គង់សមាជិកក្នុងគ្រួសារក្នុងបន្ទុកប្រមាណជាបួននាក់ ។

**ប្រភេទនៃប្រាក់កម្ចីដែលកម្មករ កម្មការិនី ១៥៨នាក់បានជាប់ជំពាក់ (ចំនួនកម្ចី=២២៧)**



## ចំនួនកម្ចីឥណទានដែលកម្មករ កម្មការិនី ម្នាក់ត្រូវបង់សង




## ទំហំប្រាក់កម្ចីគិតជាមធ្យម




- កម្មករ កម្មការិនី ភាគច្រើនជាប់ជំពាក់កម្ចីឥណទានយ៉ាងតិចមួយ ។ ការជាប់ជំពាក់ប្រាក់ច្រើនកន្លែង ក្នុងចំណោមអតិថិជននៃកម្ចីឥណទានខ្នាតតូច ដែលបានខ្ចីប្រាក់បន្ថែម ពីអ្នកចងការប្រាក់ឯកជន គឺមានចំនួនច្រើនគួរឱ្យកត់សម្គាល់ ។
- ការស្រាវជ្រាវកន្លងមកបានបង្ហាញថា ពេលខ្លះ មន្ត្រីឥណទានបានជំរុញឱ្យអតិថិជនរបស់ខ្លួន ខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជន ដើម្បីយកទៅសងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវិញ ។
- ទំហំប្រាក់កម្ចីមកពីអ្នកចងការប្រាក់ឯកជន និងសាច់ញាតិមានទំហំតូចជាង កម្ចីឥណទានខ្នាតតូចគិតជាមធ្យម ពីរបីដង ។
- អ្នកខ្ចីប្រាក់មិនសូវបង្ហាញពីកង្វល់ខ្លាំង ចំពោះបំណុលរបស់ពួកគាត់ជាមួយអ្នកចង់ការប្រាក់ឯកជន ឬសាច់ញាតិទេ ប៉ុន្តែពួកគាត់ខ្វល់ខ្វាយខ្លាំងចំពោះការបង់សងកម្ចីឥណទានប្រចាំខែក្នុងចំនួនដ៏ច្រើន ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ ។

## ប្រភេទនៃទ្រព្យធានា




- ៧៩% នៃកម្ចីឥណទានខ្នាតតូចទាំងអស់ បានយកប័ណ្ណសម្គាល់កម្មសិទ្ធិ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី ធ្វើជាទ្រព្យធានា ខណៈដែលភាគច្រើននៃកម្ចីឥណទានផ្សេងទៀត មិនមានទ្រព្យធានាទេ ។
- ការសិក្សាស្រាវជ្រាវកន្លងមកបានរកឃើញថា ការដាក់ប័ណ្ណសម្គាល់កម្មសិទ្ធិ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី ធ្វើជាទ្រព្យធានា គឺជាការដាក់សម្ពាធធ្ងន់ធ្ងរដល់អ្នកខ្ចីប្រាក់ ។
- ការដាក់អត្តសញ្ញាណប័ណ្ណធ្វើជាទ្រព្យធានា អាចបញ្ជាក់ថាអ្នកខ្ចីប្រាក់គ្រាន់តែតម្រូវឱ្យផ្តល់ច្បាប់ចម្លង នៃអត្តសញ្ញាណប័ណ្ណ របស់ពួកគាត់តែប៉ុណ្ណោះ នៅពេលស្នើសុំកម្ចី ។ ប៉ុន្តែអ្នកស្រាវជ្រាវពុំបានសាកសួរលំអិតបន្ថែមពីបញ្ហានេះទេ ។

**មូលហេតុនៃការជាប់ជំពាក់កម្ចីឥណទាន**




- ចម្លើយជាច្រើនត្រូវបានទទួលយក សម្រាប់មូលហេតុដែលនាំឱ្យអ្នកខ្ចីប្រាក់ សម្រេចចិត្តខ្ចីប្រាក់កម្ចី ។
- មូលហេតុសំខាន់ជាងគេ ដែលនាំឱ្យពួកគាត់ខ្ចីប្រាក់ក្នុងប្រភេទណាក៏ដោយ គឺដើម្បីយកទៅសងបំណុល ដែលមានស្រាប់។ ការអនុវត្តបែបនេះ បង្ហាញឱ្យឃើញពីការរីករាលដាលនៃការជាប់ជំពាក់បំណុលដ៏ច្រើនលើសលុប នៅក្នុងវិស័យរោងចក្រកាត់ដេរនៅក្នុងប្រទេសកម្ពុជា ។
- មូលហាតុចម្បងផ្សេងទៀត ដែលនាំឱ្យពួកគាត់ខ្ចីកម្ចីឥណទានខ្នាតតូចគឺ ដើម្បីយកទៅ "សាងសង់ផ្ទះ" ។ មូលហេតុសំខាន់ទីពីរគឺយកទៅ "សងបំណុលដែលមានស្រាប់" និង មូលហេតុ "ផ្សេងទៀត" (ជាទូទៅពួកគាត់ខ្ចីយកទៅទិញដី ឬទិញម៉ូតូ) ។
- ការចំណាយលើថ្លៃព្យាបាលជំងឺក៏ជាមូលហេតុចម្បងមួយដែលនាំឱ្យកម្មករ កម្មការិនី ជំពាក់ប្រាក់កម្ចី ។ ជារឿយៗ កម្មករកម្មការិនី ត្រូវចំណាយលើថ្លៃថែទាំសុខភាព អស់ពីហោប៉ៅ បើទោះជា ពួកគាត់បានចុះឈ្មោះជាសមាជិក នៅបេឡាជាតិរបបសន្តិសុខសង្គម ដែលជាកម្មវិធីថែទាំសុខភាពរបស់រាជរដ្ឋាភិបាលក៏ដោយ ។

**ថវិកាក្នុងគ្រួសារប្រចាំខែជាមធ្យម**




- គិតជាមធ្យម កម្មករ កម្មការិនី ម្នាក់ចំណាយប្រាក់សម្រាប់បង់សងកម្ចីឥណទាន និងទិញម្ហូបអាហារច្រើនជាងចំណូលប្រចាំខែដែលពួកគាត់រកបាន ។
- គិតជាមធ្យម ប្រាក់ចំណាយលើការបង់សងបំណុល ច្រើនជាងពាក់កណ្តាលនៃប្រាក់ខែរបស់ពួកគាត់ ។
- សព្វថ្ងៃនេះ ប្រាក់ឈ្នួលអប្បបរមា នៅក្នុងវិស័យរោងចក្រកាត់ដេរគឺ ១៩០ដុល្លារក្នុងមួយខែ ។ នៅឆ្នាំ២០២០ អង្គការ The Asia Floor Wage Alliance បានរកឃើញថា ប្រាក់ឈ្នួលសមរម្យប្រចាំខែ នៅក្នុងប្រទេសកម្ពុជាគឺ ២.៣៥០.៨៦៧ រៀល ឬប្រហែលនឹង ៥៧៣ ដុល្លារ ។

**វិធីសាស្ត្របង់សងបំណុលឥណទានខ្នាតតូច**




- អ្នកខ្ចីកម្ចីឥណទានភាគច្រើន បានកាត់បន្ថយការបរិភោគអាហារ ដើម្បីសន្សំប្រាក់ទុកសម្រាប់បង់សងបំណុល ដែលករណីនេះ ដូចគ្នាទៅនឹងការរកឃើញ នៅក្នុងរបាយការណ៍របស់អង្គការសិទ្ធិមនុស្ស និងវិនិយោគិនក្នុងវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាផងដែរ ។
- អ្នកខ្ចីប្រាក់ចំនួន១៥% បានលក់ដីដើម្បីសងកម្ចីឥណទានខ្នាតតូចរបស់ពួកគាត់ខណៈ ដែលអ្នកខ្ចីប្រាក់៣០% ផ្សេងទៀតគ្រោងនឹងលក់ដីដើម្បីសងកម្ចីឥណទាននៅក្នុងពេលខាងមុខ។
- អ្នកជំពាក់ប្រាក់កម្ចីប្រមាណជាង ១៥% បានធ្វើចំណាកស្រុកដើម្បីរកប្រាក់មកសងបំណុល ដែលក្នុងបរិបទនៃការសិក្សានេះគឺសំដៅលើ ការចំណាកស្រុក នៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ។
- ប្រហែលជាពាក់កណ្ដាល នៃអ្នកខ្ចីកម្ចីឥណទានខ្នាតតូច បានរាយការណ៍ថា ពួកគាត់ខ្ចីប្រាក់ បន្ថែមផ្សេងទៀត ដើម្បីយកទៅសងបំណុល ។
- គ្រប់តួលេខនៃអ្នកខ្ចីប្រាក់ ដែលលក់ដី កាត់បន្ថយការបរិភោគអាហារ ឬបញ្ឈប់កូនមិនឱ្យទៅរៀនសូត្រ ដើម្បីសងបំណុល គួរតែមិនអាចទទួលយកបានទេ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងវិនិយោគិន ។ ការរងសម្ពាធ ដែលនាំឱ្យមានការលក់ដី ការកាត់បន្ថយការបរិភោគអាហារ ការបញ្ឈប់កូនមិនឱ្យបន្តការសិក្សា ការធ្វើចំណាកស្រុក ឬការលក់ទ្រព្យសម្បត្តិដូចជាម៉ូតូ ដើម្បីសងកម្ចីឥណទានបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា វិស័យឥណទានខ្នាតតូចនៅប្រទេសកម្ពុជាពុំបានជួយលើកកម្ពស់សុខមាលភាព និងសិទ្ធិមនុស្សរបស់អ្នកជំពាក់ប្រាក់ជាអាទិភាពនោះទេ ។



**ការផ្លាស់ប្តូរកម្រិតជីវភាពរស់នៅបន្ទាប់ពីជំពាក់កម្ចីឥណទានខ្នាតតូច**




**លទ្ធភាពក្នុងការបង់សងបំណុលជាមួយនឹងចំណូលនៅក្រោយពេលព្យួរការងាររោងចក្រ និង/ឬការងាររដ្ឋ**




- ភាគច្រើន នៃអ្នកជំពាក់កម្ចីឥណទានខ្នាតតូច (៨១%) បានលើកឡើងថា កម្រិតជីវភាពរស់នៅរបស់ពួកគាត់កាន់តែ "លំបាកខ្លាំង" បន្ទាប់ពីខ្ចីកម្ចីឥណទាន ។ អ្នកជំពាក់ប្រាក់ ១៥% ផ្សេងទៀត បានរៀបរាប់ថា កម្រិតជីវភាពរស់នៅរបស់ពួកគាត់ "លំបាកតិចតួច" ។
- អ្នកជំពាក់ប្រាក់ត្រឹមតែ ២% ប៉ុណ្ណោះ ដែលបានរាយការណ៍ថា កម្រិតជីវភាពរស់នៅរបស់ពួកគាត់ "ពុំមានការប្រែប្រួលអ្វីទាំងអស់" ឬ "គ្រាន់បើជាងមុនបន្តិច" ខណៈដែលគ្មានអ្នកណាម្នាក់រាយការណ៍ថា កម្រិតជីវភាពរស់នៅរបស់ពួកគាត់ "ប្រសើរឡើងខ្លាំង" ជាងមុននោះទេ បន្ទាប់ពីខ្ចីកម្ចីឥណទាន ។
- គេអាចបកស្រាយជាទូទៅចំពោះចម្លើយទាំងនេះថាអ្នកខ្ចីប្រាក់ទទួលរងសម្ពាធ ដោយសារត្រូវបង់សងប្រាក់កម្ចី ខណៈពេលដែល ពួកគាត់មិនមានប្រាក់ចំណូលគ្រប់គ្រាន់ ហើយពួកគាត់ភ័យខ្លាច ចំពោះការដែលត្រូវលក់ដី ដើម្បីសងបំណុល។ អ្នកខ្លះបានលើកឡើងថា ពួកគាត់មិនអាចគេងលក់ស្រួលឬមានអារម្មណ៍ល្អ ដោយសារតែ ពួកគាត់បរិភោគអាហារមិនគ្រប់គ្រាន់ ។
- អ្នកខ្ចីប្រាក់ស្ទើរតែទាំងអស់ (៩៥%) បាននិយាយថា ពួកគាត់នឹងគ្មានលទ្ធភាព ដើម្បីបង់សងកម្ចីឥណទានវិញនោះទេ ប្រសិនបើរោងចក្រ ដែលពួកគាត់ធ្វើការ ត្រូវផ្អាកដំណើរការ ទោះបីជាពួកគាត់ទទួលបានប្រាក់ឧបត្ថម្ភមួយចំនួន ពីរោងចក្រ ឬរាជរដ្ឋាភិបាលក៏ដោយ ។
- រាជរដ្ឋាភិបាលកម្ពុជាបានសន្យាថា នឹងផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ កម្មការិនី ចំនួន ៤០ដុល្លារក្នុងមួយខែ និងណែនាំជាគោលការណ៍ឱ្យភាគីរោងចក្រផ្តល់ប្រាក់ចំនួន ៣០ដុល្លារបន្ថែមទៀត ប៉ុន្តែកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភនេះ មិនទាន់ត្រូវបានអនុវត្តឱ្យបានទូលំទូលាយ និងដូចគ្នានៅគ្រប់រោងចក្រនៅឡើយនោះទេ ។
- ចំនួនទឹកប្រាក់នេះ មិនគ្រប់គ្រាន់សម្រាប់អ្នកខ្ចីប្រាក់ ដើម្បីរ៉ាប់រងលើការចំណាយចាំបាច់ និងការបង់សងបំណុលទេ។ បញ្ហានេះចោទជាសំណួរដ៏គួរឱ្យព្រួយបារម្ភថាតើ កម្មករ កម្មការិនី ដែលជាអ្នកខ្ចីប្រាក់ នឹងត្រូវរងសម្ពាធ ឬត្រូវបានបង្ខំ ឱ្យប្រើប្រាស់មធ្យោបាយសងបំណុលបែបណា នៅពេលខាងមុខ ។

## ខ្ចីប្រាក់ដើម្បីសងប្រាក់

*អ្នកស្រី បុប្ផា អាយុ៣៩ឆ្នាំ មកពីខេត្តតាកែវ ជាកម្មការិនីនៅក្នុងរោងចក្រកាត់ដេរមួយ ដែលផ្គត់ផ្គង់ផលិតផលឱ្យម៉ាកអន្តរជាតិដូចជា* Adidas *និង* New Balance *។ រោងចក្រមួយនេះបានអនុញ្ញាតឱ្យអ្នកស្រីបុប្ផាឈប់សម្រាកក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ ដើម្បីទៅមើលថែម្ដាយឈឺនៅឯស្រុកកំណើត ។ ពីរថ្ងៃបន្ទាប់ពីអ្នកស្រីមកដល់ផ្ទះ ម្ដាយអ្នកស្រីក៏បានទទួលមរណៈភាព ហើយរោងចក្រក៏អនុញ្ញាតច្បាប់បន្តដើម្បីឱ្យអ្នកស្រីនៅធ្វើបុណ្យសពម្ដាយ ។*

*នៅពេលមកដល់រាជធានីភ្នំពេញវិញ ខាងរោងចក្របានប្រាប់អ្នកស្រីថា គេបានព្យួរការងាររបស់អ្នកស្រីជាមួយនិងកម្មករ កម្មការិនីផ្សេងទៀតចំនួន ៦០០នាក់ អស់រយៈពេលពីរខែមកហើយ និងតម្រូវឱ្យអ្នកស្រីធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ។ រោងចក្របានបង្ខំអ្នកស្រីឱ្យដាក់ពាក្យលាឈប់ តែអ្នកស្រីមិនយល់ព្រម ព្រោះអ្នកស្រីមិនអាចរកការងារថ្មីបានដោយងាយស្រួលនោះទេ ។ ម្យ៉ាងទៀតបើឈប់នោះអ្នកស្រីនឹងបាត់បង់អត្ថប្រយោជន៍ដែលនៅសេសសល់មួយចំនួនដូចជា ការទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃតាមរយៈបេឡាជាតិរបបសន្តិសុខសង្គមជាដើម ។*

*អ្នកស្រីបុប្ផា និងបងប្រុសរបស់អ្នកស្រីត្រូវសងបំណុលធនាគារអេស៊ីលីដា ដែលមានដាក់ប័ណ្ណសម្គាល់កម្មសិទ្ធិ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី របស់បងប្រុសអ្នកស្រីធ្វើជាទ្រព្យធានា ។ កម្ចីឥណទានដែលជាចំណែកទទួលខុសត្រូវរបស់អ្នកស្រីមានចំនួនប្រហែលជា ១.៤០០ដុល្លារ ដែលត្រូវបង់សងប្រចាំខែចំនួន ១០៦ដុល្លារ ។ អ្នកស្រីបុប្ផា និងស្វាមីបានខ្ចីប្រាក់នេះ ដើម្បីយកទៅសងកម្ចីឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងមួយទៀត ដោយបានយកម៉ូតូដាក់ជាទ្រព្យធានា ។ អ្នកស្រី និងស្វាមី ក៏មានជំពាក់ប្រាក់អ្នកចងការប្រាក់ឯកជន ដែលបានយកទៅបង់សងកម្ចីឥណទានដែលមានស្រាប់ និងសម្រាប់ផ្គត់ផ្គង់ការចំណាយប្រចាំថ្ងៃ ។ កាលពីមុន អ្នកស្រីខ្ចីប្រាក់ពីសាច់ញាតិដើម្បីយកទៅសងបំណុល ប៉ុន្តែពេលនេះ សាច់ញាតិរបស់អ្នកស្រី ក៏កំពុងជួបប្រទះបញ្ហាហិរញ្ញវត្ថុដូចគ្នា ហើយក៏កំពុងពិចារណាខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជនផងដែរ ។*

*អ្នកស្រីបុប្ផា និងស្វាមីគឺជាអ្នករកប្រាក់ចំណូលសំខាន់នៅក្នុងគ្រួសារ ដោយមានកូនៗចំនួនបីនាក់នៅក្នុងបន្ទុក ។ គ្រួសារមួយនេះបានកាត់បន្ថយការចំណាយលើថ្លៃម្ហូបអាហារ និងតែងបារម្ភថាតើពួកគាត់នឹងដោះស្រាយយ៉ាងណា ប្រសិនបើពួកគាត់ជួបបញ្ហាសុខភាពនោះ ។ អ្នកស្រីបាននិយាយថា៖ "ខ្ញុំពិតជាព្រួយបារម្ភខ្លាំងណាស់ នៅពេលខ្ញុំមិនអាចជួយសម្រួលបន្ទុកគ្រួសារបាន" ។*

# អនុសាសន៍

អនុសាសន៍ទាំងអស់ នៅក្នុងរបាយការណ៍នេះ ធ្លាប់ត្រូវបានបោះពុម្ពផ្សាយម្តងរួចមកហើយដោយអង្គការសិទ្ធិមនុស្ស ឬសហជីពកម្មករនៅក្នុងប្រទេសកម្ពុជា ។ ទោះបីជាអនុសាសន៍ទាំងនេះ មិនមែនជាអនុសាសន៍ថ្មី ប៉ុន្តែមានភាពចាំបាច់បន្ទាន់ថ្មី ដែលទាមទារឱ្យអនុវត្តនូវអនុសាសន៍ទាំងនេះ អំឡុងពេលរងផលប៉ះពាល់ ផ្នែកសេដ្ឋកិច្ចបង្កដោយការរីករាលដាលនៃវីរុសកូវីដ១៩ ជាពិសេស នៅក្នុងវិស័យកាត់ដេរតែម្តង ។ វិនិយោគិនបរទេសមិនបានយកចិត្តទុកដាក់ អស់រយៈពេលយូរណាស់មកហើយ នូវសញ្ញាគួរឱ្យព្រួយបារម្ភ នៅក្នុងវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយអ្នកទាំងនោះគួរតែចាត់វិធានការឱ្យបានឆាប់ដើម្បីធានាថាការវិនិយោគរបស់ពួកគេ មិនបាននាំឱ្យមានការរំលោភសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋកម្ពុជាអ្នកខ្ចីប្រាក់ ។ យើងខ្ញុំក៏សង្ឃឹមថារាជរដ្ឋាភិបាលកម្ពុជា អាចបង្កើនការការពារដល់អ្នកជំពាក់ កម្ចីឥណទានដើម្បីធានាថា គ្មានអ្នកណាម្នាក់ត្រូវបានបង្ខំឱ្យលក់ដី ឬត្រូវទទួលរងការរំលោភបំពានផ្សេងទៀត នៅក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ចនេះ ។ អ្នកផ្តល់ឥណទានខ្នាតតូច នៅក្នុងប្រទេសកម្ពុជា គួរធានាថាពួកគេនឹងមិនធ្វើឱ្យមានការរំលោភសិទ្ធិមនុស្សលើអ្នកខ្ចីប្រាក់ ក្នុងការធានាសុវត្ថិភាពនៃការបង់សងកម្ចីឥណទានរបស់ខ្លួន ។

### សម្រាប់ក្រុមហ៊ុនបញ្ជាទិញ និងអ្នកផ្គត់ផ្គង់

១. គួររៀបចំថវិកាសង្គ្រោះបន្ទាន់ សម្រាប់កម្មករនិយោជិតដែលត្រូវបានព្យួរពីការងារ ។

២. គួរគណនាទិន្នន័យកម្រិតតម្រូវការផលិតកម្មអប្បបរមា ដើម្បីធានាថារោងចក្រនៅដំណើរការ រួមទាំងការបាត់បង់សមត្ថភាពផ្នែកសង្វាក់ផលិតកម្ម និងប្រសិទ្ធភាព អំឡុងពេល ការរីករាលដាលនៃវីរុសកូវីដ១៩ និងវិធានការបង្ការនានា ។

### សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

១. យើងខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជាអាចធានាបានថា គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ពិតជាបានផ្អាកការបង់សងប្រាក់កម្ចី និងការប្រាក់ នៅក្នុងរយៈពេលយ៉ាងតិច៣ខែ ។

២. និងអាចធានាបានថា គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ពិតជាបានប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីរាប់លានប្លង់ដែលត្រូវបានដាក់ជាទ្រព្យធានា ឱ្យទៅម្ចាស់ទ្រព្យវិញ ។

### សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារដែលផ្តល់ឥណទានខ្នាតតូច

១. សូមស្នើឱ្យកែប្រែគោលការណ៍ផ្ទៃក្នុង ដើម្បីបញ្ឈប់ការយកប័ណ្ណសម្គាល់កម្មសិទ្ធិ ឬលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី ធ្វើជាទ្រព្យធានាសម្រាប់ការផ្តល់កម្ចីខ្នាតតូចថ្មីទាំងអស់ ។

២. និងផ្អាកការបង់សងបំណុលឥណទានខ្នាតតូច និងការប្រាក់ក្នុងរយៈពេលយ៉ាងតិច៣ខែ និងអាចពន្យាពេលលើសពីនេះដល់អ្នកខ្ចីប្រាក់ទាំងអស់ដែលទទួលរងផលប៉ះពាល់សេដ្ឋកិច្ចដោយសារការរីករាលដាលនៃវីរុសកូវីដ១៩។

### សម្រាប់វិនិយោគិនបរទេស និងដៃគូអភិវឌ្ឍន៍

១. គួរសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អភិវឌ្ឍអន្តរជាតិ ដើម្បីបង្កើតកម្មវិធីសម្រាលបន្ទុកបំណុល ដើម្បីធានាឱ្យបានថា អតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនត្រូវរងការបង្ខិតបង្ខំឱ្យលក់ដី ដើម្បីសងបំណុលនោះទេ ដែលគោលបំណងសំខាន់នៃវិធានការនេះគឺ ដើម្បីលុបបំបាត់ទាំងស្រុងនូវការលក់ដីធ្លីដោយបង្ខំ ។

២. គួរធ្វើការស៊ើបអង្កេត និងស្រាវជ្រាវលំអិតឱ្យបានទំលំទូលាយបន្ថែម ពីបញ្ហារំលោភសិទ្ធិមនុស្សដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា និងបង្កើតឱ្យមានយន្តការចុះឃ្លាំមើលជាទៀងទាត់ និងតឹងរឹងបំផុត ដើម្បីវាយតម្លៃពីស្ថានភាពជាក់ស្តែងរបស់អ្នកខ្ចីប្រាក់នៅក្នុងប្រទេសកម្ពុជា ៕